Phone: 617-694-5949
Fax: 617-859-9993
info@projectcitizenship.org

## តើ Project Citizenship ធ្វើអ្វីខ្លះ?

Project Citizenship ជួយជនអន្តោប្រវេសន៍ឲ្យបានសញ្ជាតិអាមេរិកតាមផ្លូវច្បាប់ ។ ពួកយើងគឺជាក្រុមមេធាវីខាងច្បាប់អន្តោប្រវេសន៍ ។ សេវាទាំងអស់នឹងត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃ ។

## ហេតុអ្វីបានជាត្រូវចូលសញ្ជាតិអាមេរិក?

រាល់ឆ្នាំ មនុស្សប្រហែល ៧០០ ០០០ នាក់បានចូលសញ្ជាតិអាមេរិក ។ អ្នកមានសញ្ជាតិអាមេរិកទទួលបានផលប្រយោជន៍ និងបុព្វសិទ្ធិច្រើនយ៉ាង៖

1. ការបោះឆ្នោត៖ សិទ្ធិក្នុងការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងជ្រើសរើសមន្ត្រីដទៃទៀត ដែលជាបុព្វសិទ្ធិរបស់អ្នកមានសញ្ជាតិអាមេរិក ។ មានតែអ្នកមានសញ្ជាតិអាមេរិកប៉ុណ្ណោះដែលអាចបោះឆ្នោតរដ្ឋាភិបាលថ្នាក់សហព័ន្ធ ។ បេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតថ្នាក់មូលដ្ឋាន ថ្នាក់រដ្ឋ និងថ្នាក់សហព័ន្ធត្រូវតែជាអ្នកមានសញ្ជាតិអាមេរិក ។
2. ការធានាសមាជិកគ្រួសារ៖ អ្នកមានសញ្ជាតិអាមេរិកអាចធានាសមាជិកគ្រួសារដែលរស់នៅប្រទេសផ្សេងៗ មករស់នៅសហរដ្ឋអាមេរិកបាន ។ សាច់ញាតិរបស់អ្នកមានសញ្ជាតិអាមេរិកទទួលបានអាទិភាពពីមន្ត្រីអន្តោប្រវេសន៍។
3. ការរស់នៅសហរដ្ឋអាមេរិកជានិរន្តរ៍៖ ក្នុងឋានៈជាអ្នកមានសញ្ជាតិអាមេរិកមួយរូប គ្មាននរណាម្នាក់អាចដកហូតសិទ្ធិរស់នៅប្រទេសអាមេរិករបស់អ្នកនោះទេ ។
4. ការទទួលបានសញ្ជាតិសម្រាប់កូន៖ កូនដែលមានអាយុក្រោម ១៨ ឆ្នាំនឹងទទួលបានសញ្ជាតិអាមេរិកដោយស្វ័យប្រវត្តិពេលដែលឳពុកម្តាយរបស់ពួកគេចូលសញ្ជាតិអាមេរិក ។
5. ការទទួលបានជំនួយពីរដ្ឋាភិបាល៖ ជំនួយរដ្ឋាភិបាលមួយចំនួនមានសម្រាប់អ្នកមានសញ្ជាតិអាមេរិកប៉ុណ្ណោះ ។
6. ការធ្វើដំណើរជាមួយនឹងលិខិតឆ្លងដែនរបស់សហរដ្ឋអាមេរិក៖ ការធ្វើដំណើរមានភាពងាយស្រួល ។ គ្មានការដាក់កំហិតលើរយៈពេលនៃការធ្វើដំណើរទេ ។
7. មិនចាំបាច់សុំបន្តបណ្ណសិទ្ធិរស់នៅសហរដ្ឋអាមេរិក (Green Card) ៖ អ្នកមានសញ្ជាតិអាមេរិក មានសិទ្ធិរស់នៅជាអចិន្ត្រៃយ៍  និងមិនបាច់បន្តសុំសិទ្ធិរស់នៅឡើយ។
8. ការធ្វើដំណើរដោយសុវត្ថិភាព៖ ស្ថានទូត និងកុងស៊ុលរបស់សហរដ្ឋអាមេរិកនឹងការពារពលរដ្ឋដែលមានសញ្ជាតិអាមេរិក នៅពេលពួកគេស្នាក់នៅក្រៅប្រទេស ។ រដ្ឋាភិបាលអាមេរិកនឹងជួយអ្នកមានសញ្ជាតិអាមេរិកទាំងឡាយដែលជាជនរងគ្រោះនៃអំពើឧក្រិដ្ឋទាំងឡាយក្នុងអំឡុងពេលស្នាក់នៅក្រៅប្រទេស និងជួយពួកគេក្នុងករណីមានគ្រោះមហន្តរាយធម្មជាតិ ឬករណីអាសន្នដែលកើតឡើងនៅលើពិភពលោក ។
9. ការទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ការសិក្សា៖ ប្រាក់ជំនួយឧបត្ថម្ភមួយចំនួនមានសម្រាប់តែអ្នកដែលមានសញ្ជាតិអាមេរិកតែប៉ុណ្ណោះ ។
10. ការស្វែងរកការងារ៖ ការងារថ្នាក់រដ្ឋាភិបាលសហព័ន្ធភាគច្រើន គឺសម្រាប់អ្នកមានសញ្ជាតិអាមេរិកតែប៉ុណ្ណោះ ។

Phone: 617-694-5949
Fax: 617-859-9993
info@projectcitizenship.org

## តើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីដាក់ពាក្យចូលសញ្ជាតិអាមេរិកដែរឬទេ ?

អ្នកត្រូវតែ៖

1. មានអាយុ ១៨ ឆ្នាំ ។
2. មានសិទ្ធិរស់នៅសហរដ្ឋអាមេរិកយ៉ាងតិច ៥ ឆ្នាំ ( ៣ ឆ្នាំ ប្រសិនបើរៀបការជាមួយអ្នកមានសញ្ជាតិអាមេរិក ) ។
3. បានរស់នៅសហរដ្ឋអាមេរិក ៥ ឆ្នាំក្នុងឋានៈជាអ្នកមានបណ្ណស្នាក់នៅស្របច្បាប់ ( ៣ ឆ្នាំ ប្រសិនបើរៀបការជាមួយអ្នកមានសញ្ជាតិអាមេរិក ) ។
4. បានរស់នៅសហរដ្ឋអាមេរិកយ៉ាងតិច ៣០ ខែ នៃ ៥ ឆ្នាំកន្លងទៅ ( ១៨ ខែ នៃរយៈពេល ៣ ឆ្នាំចុងក្រោយ ប្រសិនបើរៀបការជាមួយអ្នកមានសញ្ជាតិអាមេរិក ) ។
5. បានរស់នៅក្នុងរដ្ឋដែលអ្នកដាក់ពាក្យសុំចូលសញ្ជាតិយ៉ាងតិច ៣ ខែ ។
6. អាចអាន សរសេរ និងនិយាយភាសាអង់គ្លេសបានខ្លះៗ ។
7. មានចំណេះដឹងមូលដ្ឋានអំពីប្រវត្តិសាស្ត្រ និងរដ្ឋាភិបាលសហរដ្ឋអាមេរិក ។
8. មានសីលធម៌ល្អ ។
9. ស្បថថានឹងស្មោះត្រង់ចំពោះសហរដ្ឋអាមេរិក និងរដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិក ។

## តើអ្នកបានដឹងទេ ?

1. អ្នកមានសញ្ជាតិអាមេរិកអាចរកប្រាក់ចំណូលបានច្រើន ។ អ្នកមានសញ្ជាតិអាមេរិកទទួលបានប្រាក់ឈ្នួលខ្ពស់ និងមានអត្រានៃភាពក្រីក្រទាបជាងអ្នកមានសិទ្ធិរស់នៅជាអចិន្ត្រៃយ៍ (Green Card) ដោយមិនគិតពីអាយុ ភេទ និងជាតិសាសន៍ទេ ។
2. អ្នកមានសញ្ជាតិអាមេរិកទទួលបានផលប្រយោជន៍ច្រើនពីច្បាប់ពន្ធដារ ។ អ្នកមានសញ្ជាតិអាមេរិកមិនចាំបាច់បង់ប្រាក់ពន្ធលើទ្រព្យដែលជាកេរមរតកនៅពេលដែលប្តី ឬប្រពន្ធស្លាប់ ។ អ្នកគ្មានសញ្ជាតិអាមេរិកត្រូវបង់ពន្ធ ៥០% នៃប្រាក់ទទួលបានសរុបនៅពេលដែលប្តី ឬប្រពន្ធស្លាប់ ។
3. អ្នកមានសិទ្ធិរស់នៅអចិន្ត្រៃយ៍គ្មានសិទ្ធិដូចអ្នកមានសញ្ជាតិអាមេរិកទេ។ អ្នកមានសិទ្ធិរស់នៅអចិន្ត្រៃយ៍នឹងប្រឈមមុខខ្លាំងនឹងការឃាត់ខ្លួន ។ អ្នកគ្មានសញ្ជាតិអាមេរិកអាចនឹងត្រូវបាននិរទេសក្រៅប្រទេសដោយមិនចាំបាច់មានសេចក្តីវិនិច្ឆ័យលើពិរុទ្ធភាពនៃបទឧក្រិតណាមួយឡើយ ។